ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
លេខ ...១៧៧...... ក.ប/ប្រ.ក.ប.ស.ស

# ប្រកាស
# ស្តីពី
# សេវាស្តារនីតិសម្បទា សម្រាប់របបសន្តិសុខសង្គមផ្នែកហានិភ័យការងារ និងផ្នែកថែទាំសុខភាព សម្រាប់ជនទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ

## រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៥/០០៣ ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០០៥ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- បានឃើញព្រះរាជក្រមលេខ ជស/រកម/០៣៩៧/០១ ចុះថ្ងៃទី១៣ ខែមីនា ឆ្នាំ១៩៩៧ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការងារ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៩០២/០១៨ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០២ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីរបបសន្តិសុខសង្គមសម្រាប់ជនទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨១៥/៨៧២ ចុះថ្ងៃទី០៨ ខែសីហា ឆ្នាំ២០១៥ ស្តីពីលក្ខន្តិកៈគតិយុត្ត នៃគ្រឹះស្ថានសាធារណៈរដ្ឋបាល
- បានឃើញអនុក្រឹត្យលេខ ២៨៣ អនក្រ/បក ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០១៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- បានឃើញអនុក្រឹត្យលេខ ១៦ អនក្រ/បក ចុះថ្ងៃទី០២ ខែមីនា ឆ្នាំ២០០៧ ស្តីពីការបង្កើតបេឡាជាតិរបបសន្តិសុខសង្គម



អាសយដ្ឋាន អគារលេខ៣ មហាវិថីសហព័ន្ធរុស្ស៊ី សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក ទូរស័ព្ទ:(០២៣)៨៨ ៤៣ ៧៥ និងទូរសារ :(០២៣)៨៨ ២៧ ៦៩

- បានឃើញអនុក្រឹត្យលេខ ០១ អនក្រ/បក ចុះថ្ងៃទី០៦ ខែមករា ឆ្នាំ២០១៦ ស្ដីពីការបង្កើតរបបសន្តិសុខសង្គមផ្នែកថែទាំសុខភាព សម្រាប់ជនទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្ដីពីការងារ
- បានឃើញប្រកាសលេខ ១០៩ កប/ប្រក ចុះថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០០៨ ស្ដីពីតារកាលិកហានិភ័យការងារ
- បានឃើញប្រកាសលេខ១០៩ កប/ប្រក ចុះថ្ងៃទី១៧ ខែមីនា ឆ្នាំ២០១៦ ស្ដីពីតារកាលិកថែទាំសុខភាព
- យោងតាមសំណើរបស់ក្រុមប្រឹក្សាភិបាលនៃបេឡាជាតិរបបសន្តិសុខសង្គម

# សម្រេច

## ជំពូកទី១

## បទប្បញ្ញត្តិទូទៅ

**ប្រការ ១.-**

ប្រកាសនេះ មានគោលបំណងកំណត់សេវាស្ដារនីតិសម្បទា សម្រាប់របបសន្តិសុខសង្គមផ្នែកហានិភ័យការងារ និងផ្នែកថែទាំសុខភាព សម្រាប់កម្មករនិយោជិតដែលស្ថិតនៅក្នុងដែនអនុវត្តនៃច្បាប់ស្ដីពី របបសន្តិសុខសង្គមសម្រាប់ជនទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្ដីពីការងារ។

**ប្រការ ២.-**

ប្រកាសនេះ មានគោលដៅកំណត់អំពីបែបបទ និងនីតិវិធី នៃការផ្ដល់សេវាស្ដារនីតិសម្បទា ដែលស្ថិតនៅក្នុងដែនអនុវត្តនៃច្បាប់ស្ដីពី របបសន្តិសុខសង្គមសម្រាប់ជនទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្ដីពីការងារ នូវសេវាស្ដារនីតិសម្បទាផ្នែកវេជ្ជសាស្ត្រ សេវាស្ដារនីតិសម្បទាផ្នែកបណ្ដុះបណ្ដាលវិជ្ជាជីវៈឡើងវិញ និងសេវាស្ដារនីតិសម្បទាផ្នែកសង្គម សម្រាប់របបសន្តិសុខសង្គម ផ្នែកហានិភ័យការងារ និងផ្នែកថែទាំសុខភាព។

**ប្រការ ៣.-**

ប្រកាសនេះ មានវិសាលភាពអនុវត្ត ចំពោះកម្មករនិយោជិតជាសមាជិក ប.ស.ស ដែលស្ថិតនៅក្នុងដែនអនុវត្តនៃច្បាប់ស្ដីពីរបបសន្តិសុខសង្គមសម្រាប់ជនទាំងឡាយ ដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្ដីពីការងារ។

**ប្រការ ៤.-**

វាក្យស័ព្ទបច្ចេកទេសសំខាន់ៗ ដែលប្រើនៅក្នុងប្រកាសនេះ មានចែងក្នុងឧបសម្ព័ន្ធ១ នៃប្រកាសនេះ។

## ជំពូកទី២
## បែបបទ និងនីតិវិធី នៃការផ្តល់សេវាស្តារនីតិសម្បទា
## ផ្នែកទី១
## គោលការណ៍រួម

**ប្រការ ៥.-**

ការស្នើសុំសេវាស្តារនីតិសម្បទា ត្រូវធ្វើឡើងតាមរយៈទម្រង់ "ពាក្យស្នើសុំសេវាស្តារនីតិសម្បទា" ដូចមានចែងនៅក្នុងឧបសម្ព័ន្ធ២ នៃប្រកាសនេះ ដោយមានភ្ជាប់មកជាមួយនូវវេជ្ជបញ្ជារបស់គ្រូពេទ្យ ឬអ្នកឯកទេសដែលទទួលស្គាល់ដោយ ប.ស.ស ឬ ឯកសារពាក់ព័ន្ធចាំបាច់ដទៃទៀត។

ជនពិការត្រូវមកបង្ហាញខ្លួននៅបេឡាជាតិរបបសន្តិសុខសង្គម ដើម្បីពិនិត្យ វាយតម្លៃ និងតម្រង់ទិសការផ្តល់សេវា។ ក្នុងករណីដែលជនពិការ មិនអាចបង្ហាញខ្លួនក្នុងការស្នើសុំ ដោយសារស្ថានភាពពិការភាពមានសភាពធ្ងន់ធ្ងរ ការស្នើសុំនេះ អាចត្រូវធ្វើឡើងដោយអ្នកតំណាង។ អ្នកតំណាងអាចជាសហព័ទ្ធ កូន ឬ ជនដែលមានភារៈថែរក្សាដោយផ្ទាល់ចំពោះជនពិការ។

**ប្រការ ៦.-**

សេវាស្តារនីតិសម្បទា ដែលត្រូវបានទទួលការយល់ព្រមពីបេឡាជាតិរបបសន្តិសុខសង្គម លុះត្រាតែធ្វើឡើងដោយមានការអនុញ្ញាត ឬ នៅក្នុងមជ្ឈមណ្ឌល ឬ អង្គភាពផ្តល់សេវាស្តារនីតិសម្បទា ដែលកំណត់ដោយបេឡាជាតិរបបសន្តិសុខសង្គម។

ជនពិការត្រូវមានភាពសមស្របនូវលក្ខខណ្ឌកាយសម្បទា សតិបញ្ញា កត្តាជំរុញ ឬសមត្ថភាពដែលអាចជំរុញបាន ព្រមទាំងឆន្ទៈសហការជាមួយអ្នកផ្តល់សេវា ដើម្បីទទួលយកបាននូវការផ្តល់សេវាស្តារនីតិសម្បទា។

ជនពិការត្រូវមានកាតព្វកិច្ចថែរក្សាអវយវៈសិប្បនិម្មិត រណប ឬឧបករណ៍ជំនួយ ដែលបានផ្តល់ ស្របតាមការកំណត់របស់បេឡាជាតិរបបសន្តិសុខសង្គម។

សេវាស្តារនីតិសម្បទាដែលត្រូវបានផ្តល់ជូន ត្រូវអនុលោមតាមស្ថានភាពសេដ្ឋកិច្ចសង្គមជាក់ស្តែង។

**ប្រការ ៧.-**

ការផ្តល់សេវាស្តារនីតិសម្បទា ឬការចំណាយដែលពាក់ព័ន្ធនឹងការផ្តល់សេវា ដូចមានចែងក្នុងប្រកាសនេះ ត្រូវស្ថិតក្នុងបន្ទុករបស់បេឡាជាតិរបបសន្តិសុខសង្គម។

## ផ្នែកទី២
## ផ្នែកហានិភ័យការងារ

**ប្រការ ៨.-**

កម្មករនិយោជិតជាសមាជិកបេឡាជាតិរបបសន្តិសុខសង្គម ដែលទទួលរងហានិភ័យការងារបណ្តាលឲ្យបាត់បង់សមត្ថភាពការងារជាអចិន្ត្រៃយ៍ មានសិទ្ធិទទួលបានសេវាស្តារនីតិសម្បទាផ្នែកវេជ្ជសាស្ត្រ ឬ សេវាស្តារនីតិសម្បទាផ្នែកបណ្តុះបណ្តាលវិជ្ជាជីវៈឡើងវិញ ឬ សេវាស្តារនីតិសម្បទាផ្នែកសង្គម។

**ប្រការ ៩.-**

សេវាស្តារនីតិសម្បទាផ្នែកវេជ្ជសាស្ត្រ ត្រូវបានផ្តល់ជូនសមាជិកបេឡាជាតិរបបសន្តិសុខសង្គម ដែលទទួលរងហានិភ័យការងារ សម្រាប់គាំទ្រដល់ការព្យាបាល និងថែទាំវេជ្ជសាស្ត្រ ឬ បន្ទាប់ពីទទួលបានសេវាព្យាបាល និងថែទាំវេជ្ជសាស្ត្រ ហើយបាត់បង់សមត្ថភាពការងារជាអចិន្ត្រៃយ៍។

**ប្រការ ១០.-**

ការបណ្តុះបណ្តាលវិជ្ជាជីវៈឡើងវិញ ត្រូវបានផ្តល់ជូនជនពិការ ដើម្បីមានឱកាសទទួលបានការងារជាថ្មី ឬ ប្រកបមុខរបរផ្ទាល់ខ្លួន។ ជនពិការត្រូវមានលក្ខខណ្ឌកាយសម្បទា និងសតិបញ្ញាសមស្រប ដើម្បីទទួលបានការបណ្តុះបណ្តាលវិជ្ជាជីវៈឡើងវិញ។

ការបណ្តុះបណ្តាលវិជ្ជាជីវៈឡើងវិញ ត្រូវបានផ្តល់ជូនរយៈពេលយ៉ាងយូរ ០១ (មួយ)ឆ្នាំ។

ជនពិការដែលមានលក្ខណៈសម្បត្តិ និងសមត្ថភាពបំពេញនូវមុខងារ តួនាទី និងការទទួលខុសត្រូវក្នុងមុខតំណែង អាចទទួលបានការជួយសម្របសម្រួលរកការងារឲ្យធ្វើ។

**ប្រការ ១១.-**

ជនពិការអាចទទួលបាននូវការប្រឹក្សា ការតម្រង់ទិស ការអប់រំចិត្តសាស្ត្រ និងសេវាស្តារនីតិសម្បទាផ្នែកសង្គមនានា ក្នុងគោលបំណងធ្វើឲ្យប្រសើរឡើងផ្នែកចិត្តសាស្ត្រសង្គម ទទួលបាននូវភាពម្ចាស់ការ និងសេចក្តីត្រូវការសម្រាប់ការរស់នៅប្រចាំថ្ងៃ។

## ផ្នែកទី៣
## ផ្នែកថែទាំសុខភាព

**ប្រការ ១២.-**

កម្មករនិយោជិតជាសមាជិកបេឡាជាតិរបបសន្តិសុខសង្គម ដែលទទួលរងគ្រោះថ្នាក់ ឬជំងឺ ក្រៅពីហានិភ័យការងារ ត្រូវទទួលបានតែសេវាស្តារនីតិសម្បទាផ្នែកវេជ្ជសាស្ត្រប៉ុណ្ណោះ។

**ប្រការ ១៣.-**

សេវាស្ថានីតិសម្បទាផ្នែកវេជ្ជសាស្ត្រ ត្រូវបានផ្តល់ជូនសម្រាប់គាំទ្រដល់ការព្យាបាល និងថែទាំវេជ្ជសាស្ត្រ ឬ បន្ទាប់ពីទទួលបានសេវាព្យាបាល និងថែទាំវេជ្ជសាស្ត្រ ហើយទទួលរងពិការភាព។

## ជំពូកទី៣
## អន្តរប្បញ្ញត្តិ

**ប្រការ ១៤.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះ ត្រូវចាត់ទុកជានិរាករណ៍។

## ជំពូកទី៤
## អវសានប្បញ្ញត្តិ

**ប្រការ ១៥.-**

ប្រកាសនេះ មានប្រសិទ្ធភាពអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ អង្គារ ៨កើត ខែ អស្សុជ ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៦ ខែ តុលា ឆ្នាំ២០១៨

**រដ្ឋមន្ត្រី**

**អ៊ិត សំហេង**

**កន្លែងទទួល៖**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យ សម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ
- ក្រុមប្រឹក្សាភិបាលនៃ ប.ស.ស
  "ដើម្បីជូនជ្រាប"
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

## វាក្យស័ព្ទបច្ចេកទេស

- ***សេវាស្តារនីតិសម្បទា*** **(Rehabilitation)** សំដៅដល់ការផ្តល់សេវាស្តារនីតិសម្បទា ឬសេវាបុននីតិសម្បទាផ្នែកវេជ្ជសាស្ត្រ ការបណ្តុះបណ្តាលវិជ្ជាជីវៈឡើងវិញ និងសេវាសង្គម ក្នុងគោលបំណងជួយដល់ជនពិការអាចរក្សា ស្តារ ឬធ្វើឲ្យប្រសើរឡើងវិញនូវសមត្ថភាពជំនាញ និងមុខងារសម្រាប់ការរស់នៅប្រចាំថ្ងៃ ដែលបានបាត់បង់ ឬខូចខាតដោយសារជំងឺ ការរងរបួស ឬពិការភាព។
- ***សេវាស្តារនីតិសម្បទាផ្នែកវេជ្ជសាស្ត្រ*** **(Medical Rehabilitation)** សំដៅដល់ការផ្តល់ ការជួសជុល ឬការផ្តល់ជាថ្មីអវយវៈសិប្បនិម្មិត រណប ឬឧបករណ៍ជំនួយ ការហ្វឹកហាត់កាយសម្បទាឡើងវិញ ការព្យាបាលដោយចលនា និងការផ្តល់សេវាស្តារនីតិសម្បទាផ្នែកវេជ្ជសាស្ត្រដទៃទៀត។
- ***អវយវៈសិប្បនិម្មិត*** **(Prosthesis)** សំដៅដល់ឧបករណ៍សិប្បនិម្មិតខាងក្រៅ ប្រើសម្រាប់ជំនួសផ្នែកទាំងស្រុង ឬផ្នែកណាមួយ នៃអវយវៈដែលបាត់បង់។
- ***រណប*** **(Orthosis)** សំដៅដល់ឧបករណ៍ខាងក្រៅប្រើសម្រាប់អបផ្នែករាង្គកាយដែលទន់ខ្សោយសាច់ដុំ ឬខូចទ្រង់ទ្រាយ ដើម្បីជំនួយដល់ការធ្វើចលនា ឬការធ្វើការងារផ្សេងៗ។
- ***ឧបករណ៍ជំនួយ*** **(Assistive Device)** សំដៅដល់ឧបករណ៍ ឬវត្ថុ ប្រើសម្រាប់ជំនួយដល់ការចល័ត ឬការបំលាស់ទីរបស់ជនពិការ។
- ***ការហ្វឹកហាត់កាយសម្បទាឡើងវិញ*** **(Occupational Therapy)** សំដៅដល់ការហ្វឹកហាត់ ឬការព្យាបាលពិការភាពដោយអ្នកជំនាញខាងហ្វឹកហាត់កាយសម្បទា ដើម្បីអភិវឌ្ឍ ឬធ្វើឲ្យប្រសើរឡើងវិញ ឬថែរក្សាបាននូវសមត្ថភាព និងមុខងារ សម្រាប់បំពេញតម្រូវការចាំបាច់ក្នុងការរស់នៅប្រចាំថ្ងៃ។
- ***ការព្យាបាលដោយចលនា*** **(Physical Therapy)** សំដៅដល់ការព្យាបាលជំងឺ របួស ឬពិការភាពដោយប្រើវិធីរូបសាស្ត្រ ដូចជាការម៉ាស្សា ការស្ពំ ឬការធ្វើចលនា។
- ***សេវាស្តារនីតិសម្បទាផ្នែកបណ្តុះបណ្តាលវិជ្ជាជីវៈឡើងវិញ*** **(Vocational Rehabilitation)** សំដៅដល់ការតម្រង់ទិសវិជ្ជាជីវៈ ការបណ្តុះបណ្តាលវិជ្ជាជីវៈ ឬការជ្រើសរើសការងារដើម្បីជួយដល់ជនពិការទទួលបានការងារសមស្រប។
- ***សេវាស្តារនីតិសម្បទាផ្នែកសង្គម*** **(Social Rehabilitation)** សំដៅដល់ដំណើរការ នៃការធ្វើសមាហរណកម្មជនពិការចូលទៅក្នុងសង្គម ជួយឲ្យសម្របខ្លួនទៅនឹងតម្រូវការរបស់គ្រួសារ សហគមន៍ និងមុខងារសម្រាប់ការរស់នៅប្រចាំថ្ងៃ។
- ***ជនពិការ*** **(People with Disabilities)** សំដៅដល់កម្មករនិយោជិត ជាសមាជិកបេឡាជាតិរបបសន្តិសុខសង្គម ដែលទទួលរងហានិភ័យការងារ គ្រោះថ្នាក់ ឬជំងឺផ្សេងៗ បណ្តាលឲ្យបាត់បង់សមត្ថភាពការងារជាអចិន្ត្រៃយ៍។

*ឧបសម្ព័ន្ធ២ នៃប្រកាសលេខ៤៧៧/១៨ ក.ប/ប្រ.ក.ប.ស.ស ចុះថ្ងៃទី ១៦ ខែ តុលា ឆ្នាំ២០១៨ ស្តីពីសេវាស្តារនីតិសម្បទា សម្រាប់របបសន្តិសុខសង្គមផ្នែកហានិភ័យការងារ និងផ្នែកថែទាំសុខភាព សម្រាប់ជនទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ*

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

# ពាក្យស្នើសុំសេវាស្តារនីតិសម្បទា

ខ្ញុំបាទ/នាងខ្ញុំឈ្មោះ.................................. លេខអត្តសញ្ញាណកម្មករនិយោជិត..........................................
ឆ្នាំកំណើត......................... អាសយដ្ឋានអចិន្ត្រៃយ៍ផ្ទះលេខ.......... ផ្លូវលេខ........... ភូមិ..........................
ឃុំ/សង្កាត់.................. ស្រុក/ខណ្ឌ.................. ខេត្ត/ក្រុង..................... ទូរស័ព្ទលេខ............................
បម្រើការងារនៅសហគ្រាស គ្រឹះស្ថាន.............................................. លេខអត្តសញ្ញាណ.........................

**សូមគោរពជូន**
**ឯកឧត្តមប្រតិភូរាជរដ្ឋាភិបាល**
**ទទួលបន្ទុកជាអគ្គនាយកបេឡាជាតិរបបសន្តិសុខសង្គម**

**កម្មវត្ថុ៖** សំណើសុំ..........................................................................................................................។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុខាងលើ ខ្ញុំបាទ/នាងខ្ញុំ សូមជម្រាបជូន **ឯកឧត្តមប្រតិភូរាជរដ្ឋាភិបាល** មេត្តាជ្រាបថា ខ្ញុំបាទ/នាងខ្ញុំ បានទទួលរងគ្រោះថ្នាក់/ជំងឺ នៅក្នុងរបបសន្តិសុខសង្គមផ្នែក ..................... កាលពីថ្ងៃទី........ ខែ.......... ឆ្នាំ........... ដោយមូលហេតុ/រោគវិនិច្ឆ័យ........................................................... បណ្តាលឲ្យរងរបួស/ពិការ..........................................................................................។ ដូចនេះ ខ្ញុំបាទ/នាងខ្ញុំ សូមស្នើសុំសេវាស្តារនីតិសម្បទា ដូចបានលើកឡើងខាងលើ ដើម្បីសម្រួលដល់ជីវភាពប្រចាំថ្ងៃ។

អាស្រ័យហេតុដូចបានជម្រាបជូនខាងលើ សូម **ឯកឧត្តមប្រតិភូរាជរដ្ឋាភិបាល** មេត្តាពិនិត្យសម្រេចដោយសេចក្តីអនុគ្រោះ។

សូម **ឯកឧត្តមប្រតិភូរាជរដ្ឋាភិបាល** មេត្តាទទួលនូវសេចក្តីគោរពដ៏ខ្ពង់ខ្ពស់អំពីខ្ញុំបាទ/នាងខ្ញុំ។

....................ថ្ងៃទី...........ខែ...........ឆ្នាំ...........
**ស្នាមមេដៃ ឬហត្ថលេខាអ្នកស្នើសុំ**